# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

************************

## គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRMP): កម្ពុជា

# គម្រោងអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច (IPDF)

១៥ តុលា ឆ្នាំ ២០១០

# អារម្ភកថា

ឯកសារនេះត្រូវបានគេហៅថាជាគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF) សំរាប់នៅកម្ពុជា។ វាត្រូវបានគេអភិវឌ្ឍន៍ដោយឈរលើមូលដ្ឋានគ្រឹះនៃលទ្ធផលនានាដែលបានមកពីការសិក្សាសង្គម និងបរិស្ថានបឋម និងកិច្ចពិគ្រោះយោបល់នានាដែលជាឯកសារមូលដ្ឋាន។ គម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF) គឺត្រូវបានភ្ជាប់ទៅនឹងឯកសារសុវត្ថិភាពទាំងមូលដែលមានឈ្មោះថា គម្រោងគ្រប់គ្រងសង្គម និងបរិស្ថានរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRM) នៅកម្ពុជា។ គម្រោងនេះនឹងត្រូវបានអនុវត្តនូវរាល់ការវិនិយោគដែលត្រូវបានផ្តល់កិច្ចគាំទ្រថវិការដោយធនាគារពិភពលោកសំរាប់ការគាំទ្របច្ចេកទេស និងថវិការពីគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRM) នៅកម្ពុជាដែលទាក់ទងទៅនឹងជនជាតិដើមភាគតិច (OP 4.10)។

ផ្នែកគ្រប់គ្រងគម្រោង និងផ្នែកអនុវត្តគម្រោងរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលខុសត្រូវដើម្បីធានាថាស្របទៅតាមគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដោយរួមទាំងការរក្សានូវឯកសាររបស់គម្រោងដើម្បីអាចសង្ខេបតាមរយៈធនាគារពិភពលោក។

ឯកសារនេះត្រូវបានចាត់ទុកជាឯកសារសំខាន់ និងអាចត្រូវបានផ្លាស់ប្តូរ និងកែប្រែអោយស្របទៅតាមការប្រែប្រួលស្ថានភាព វីព្រំដែននៃសកម្មភាពនានា។ កិច្ចពិគ្រោះយោបល់យ៉ាងជិតស្និទ្ធិជាមួយធនាគារពិភពលោក និងការជម្រះនៃបញ្ហាទាក់ទងទៅនឹងគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិចគឺជាការចាំបាច់។

**កម្ពុជា: គម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF)**

**មាតិកាអត្ថបទ**

**ទំព័រ**

**ផ្នែកទី១: សេចក្តីផ្តើម ………...............………………………………………………3**

**ផ្នែកទី២: សាវតា ....................……………………………………………………………4**

២.១.សេចក្តីសង្ខេបនៃជនជាតិដើមភាគតិចនៅកម្ពុជា ……..............………………………………4

២.២. គម្រោងស្របច្បាប់ និងនិយតកម្ម…………...............…………………………………………4

**ផ្នែកទី៣: បញ្ហានានា និងភាពទាក់ទងនៃគម្រោងអភិវឌ្ឍន៍ជន ជាតិដើមភាគតិចទៅនឹងគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ……....................................................………………5**

៣.១. គោលនយោបាយប្រតិបត្តិធនាគារពិភពលោក: ជនជាតិដើមភាគតិច (OP 4.10) ..........................5

៣.២. ការឆ្លុះបញ្ចាំងសំរាប់ជនជាតិដើមភាគតិច និងការវាយតម្លៃផលប៉ះពាល់នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ.....................................................................................................................6

៣.៣. នីតិវិធី និងគោលការណ៍ដែលបានអនុវត្តដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង..............7

៣.៤. ការតាមដាន ការរៀបចំឯកសារ និងការរាយការណ៍របស់ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង.....................................................................................................................8

**ផ្នែកទី៤: គោលការណ៍ណែនាំបច្ចេកទេសសំរាប់គម្រោងពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចដែលទទួលរងនូវផលប៉ះពាល់ដោយការវិនិយោគ..................................................................8**

៤.១. ការឆ្លុះបញ្ចាំងតំបូង.......................................................................................................8

៤.២. ការវាយតម្លៃសង្គម…………………………………………………………………………………….9

៤.៣.ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច.........................................................................................9

៤.៤. ការរៀបចំការអនុវត្ត…...................................................................................................10

៤.៥. ការតាមដាន........................................................................................................10

៤.៦. កាលវិភាគ.........................................................................................................10

៤.៧. ថវិការ...............................................................................................................10

៤.៨. របាយការណ៍ និងឯកសារ....................................................................................11

៤.៩. តម្លាភាព និងយន្តការសារទុក្ខ.................................................................................11

ឧបសម្ពន្ធ័ទី ១: សេចក្តីលំអិតនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ.......................................12

# គម្រោងអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច (IPDF)

## ផ្នែកទី I.  សេចក្តីផ្តើម

១. គោលបំណងនៃអនុសមាសភាពគ្រប់គ្រងវិស័យជលផលនៅកម្ពុជា (អនុសមាសធាតុ ៣-២) គឺស្របទៅនឹងគោលបំណងអភិវឌ្ឍន៍នៃ គម្រោងទាំងមូលនៃការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនៅតាមអាងទន្លេមេគង្គផ្នែកខាងក្រោមថ្នាក់តំបន់ ជាតិ និងថ្នាក់អនុជាតិ និងសេចក្តីលំអិតត្រូវបានរៀបរាប់នៅក្នុងតារាង ***ឧបសម្ព័ន្ធទី ១***។

២. សកម្មភាពនៅកម្ពុជានឹងត្រូវបានកំណត់តែទៅលើអនុសមាសធាតុ ៣-២ និងសកម្មភាពទាំងនោះទាក់ទងទៅនឹងជនជាតិដើមភាគតិច។ អនុសមាសធាតុនៅកម្ពុជានឹងត្រូវបានអនុវត្តតាមរយៈសកម្មភាពដូចខាងក្រោម:

- គាំទ្រសហគមន៍នេសាទដោយរួមមាន: (ក). ការបង្កើត ការចុះបញ្ជី និងពង្រឹងស្ថាប័ននៃសហគមន៍នេសាទ (CFi) (ខ).ការគ្រប់គ្រងវិស័យជលផលទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍រៀងៗខ្លួន (ផែនការអភិវឌ្ឍន៍ឃុំ) និង (គ). ផ្តល់ដល់សហគមន៍នេសាទនូវជម្រើសមុខរបរនានា និង
- គាំទ្រផ្នែកសាធារណៈ ជាពិសេសសម្រាប់ថ្នាក់ស្រុក និងខណ្ឌរដ្ឋបាលជលផល ដើម្បីធានាសមត្ថភាពផ្នែកសាធារណៈឱ្យបានគ្រប់គ្រាន់នៅក្នុងការពិនិត្យលើការអនុវត្តន៍ផែនការគ្រប់គ្រងវិស័យជលផល តាមដានផលចាប់ត្រី លើកកំពស់វារីវប្បកម្ម និងលែងប្រភេទត្រីក្នុងស្រុកសំខាន់ៗទៅក្នុងធម្មជាតិ។

៣. លើសពីនេះ វាក៏ត្រូវបានគ្រោងផងដែរនៅក្រោមសមាសភាព ទី ១ (ការគ្រប់គ្រងធនធានទឹកថ្នាក់តំបន់ ) ដែលអាចប្រគល់ដល់គណៈកម្មការទន្លេមេគង្គ (MRC) ការគាំទ្រមួយចំនួនគួរត្រូវបានផ្តល់ដើម្បីអប់រំពីតំបន់ដែលមានធនធានរួមគ្នា (trans-boundary) និងសកម្មភាពនានាទាក់ទងទៅការគ្រប់គ្រងវិស័យជលផលនៅតាមព្រំប្រទល់កម្ពុជា និងឡាវ។

៤. ព្រំដែននៃសកម្មភាពនានានៅកម្ពុជាគួរគ្របដណ្តប់ទៅលើខ្សែទឹកមេទន្លេមេគង្គពីព្រំប្រទល់ប្រទេសឡាវមកដល់ខេត្តស្ទឹងត្រែង និងក្រចេះ។ តំបន់ទាំងនោះត្រូវបានគេស្គាល់ថាជាជម្រកដ៏សំខាន់មួយ (ជាជម្រកសុវត្ថិភាពដ៏សំខាន់នៅរដូវប្រាំង និងរដូវពងកូន) សម្រាប់ត្រីជា ច្រើនប្រភេទដែល ធ្វើការបំលាស់ទីឆ្ងាយៗរួមទាំងប្រភេទត្រីដែលងាយរងគ្រោះថ្នាក់ដូចជា ត្រីប្រាបុងឡាវ *(Pangasius krempfi)* ត្រីរាជ *(Pangasianodon gigas)* និងប្រភេទសត្វទឹកជាច្រើនទៀតដូចជា ប្រភេទផ្សោត កម្រទន្លេមេគង្គ *(freshwater dolphin…Irrawady dolphin)*។ តំបន់ទាំងនេះត្រូវបានគេស្គាល់ថាជាតំបន់ដែលមានជនជាតិដើមភាគតិចនានាតាំងទីលំនៅ និងពួកគេអាចទទួលផលប៉ះពាល់ពីគម្រោងជាអវិជ្ជមាន វិជ្ជមាន។

៥. ដើម្បីជៀសវាងផលប៉ះពាល់ជាអវិជ្ជមានទៅលើជនជាតិដើមភាគតិច និងស្របទៅតាមគោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច គម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិចត្រូវបានអភិវឌ្ឍន៍ដើម្បីធានាថាជនជាតិដើមភាគតិចទាំងនោះមានឱកាសស្មើភាពគ្នាដើម្បីចែករំលែកផលប្រយោជន៍ពីគម្រោង និងដែលផលប៉ះពាល់ជាអវិជ្ជមានត្រូវបានសម្រាលបានត្រឹមត្រូវ។ គម្រោងជនជាតិដើមភាគតិចនឹងបង្កើតមូលដ្ឋានគ្រឹះសំរាប់ការអនុវត្តគម្រោង និងសំរាប់ការតាមដាន និងវាយតម្លៃថាតើគម្រោងដោះស្រាយយ៉ាងដូចម្តេចជាមួយបញ្ហាជនជាតិដើមភាគតិច។ គម្រោងជនជាតិដើមភាគតិចអនុវត្តតាមនិយតកម្មរបស់រាជរដ្ឋាភិបាល និងគោលនយោបាយជនជាតិដើមភាគតិចរបស់ធនាគារ ពិភពលោក។

៦. ផ្នែកទី II ខាងក្រោមសង្ខេបនូវលក្ខខណ្ឌ័សាវតាទាក់ទងទៅនឹងជនជាតិដើមភាគតិច និងនិយតកម្មនៅកម្ពុជា ខណៈដែល ផ្នែកទី III រៀបរាប់ពីគោលបំណង និងគោលការណ៍គ្រឹះនៃគោលនយោបាយប្រតិបត្តិ ៤.១០ មិងរបៀបដែលត្រូវបានអនុវត្តទៅលើគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ រួមទាំងសកម្មភាពនានាដែលត្រូវបាន និង នឹងត្រូវបានអនុវត្តដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង។ ផ្នែកទី VI ផ្តល់នូវវិធានបច្ចេកទេសសំរាប់គម្រោងពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច ដែលត្រូវបានអនុវត្តកំលុងពេលនៃការរៀបចំគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ។ ព្រំដែនសំរាប់ការរៀបចំនៃផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចក៏ត្រូវបានផ្តល់ផងដែរដែលស្ថិតនៅក្រោមគម្រោងពិគ្រោះយោបល់ ប្រសិនបើផលប៉ះពាល់ជាអវិជ្ជមានលើជនជាតិដើមភាគតិចត្រូវបានប្រមើលទុកជាមុន។

# ផ្នែកទី II. សាវតា

## ២.១. សេចក្តីសង្ខេបនៃក្រុមជនជាតិដើមភាគតិចនៅកម្ពុជា

៧. ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន ១៣.៧ លាននាក់ ដែលក្នុងនោះ ៩០ ទៅ ៩៥ ភាគរយជាជនជាតិខ្មែរ។ នៅសេសសល់ពីនេះប្រមាណ ៥ ទៅ ១០ ភាគរយគឺជាជនជាតិភាគតិច ចាម ចិន និងវៀតណាម និង ១៧ ក្រុមនៃក្រុមជនជាតិដើមភាគតិចដែលគេហៅថាអ្នកស្រុកលើ “Khmer Loeu” រឺកុលសម្ពន្ធដែល រស់នៅតាមតំបន់ភ្នំ “hill tribes” ដែលមិនមែនជាជនជាតិខ្មែរ។ ក្រុមជនជាតិដើមទាំងនេះត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនប្រហែល ១២០, ០០០ នាក់ ស្មើនឹង ១ ភាគរយនៃបរិមាណប្រជាជនកម្ពុជាសរុប។ មានក្រុមជនជាតិដើមភាគតិចចំនួន ១៧ ក្រុម ដែលមានចំនួនពី ៣០០ ទៅ ១៩,០០០ នាក់ រួមមានៈ តាពួន គួយ ចារាយ ភ្នង គ្រឹងកាវែត ប្រូ ស្មៀង លុន និងក្រុមជនជាតិដើមផ្សេងៗទៀត។ ក្រុម ជនជាតិដើមភាគតិចមាននៅភាគច្រើននៅក្នុងខេត្តរតនៈគីរី (៦៧.៩ ភាគរយ) និងមណ្ឌលគីរី (៥៩.៣ ភាគរយ)។ នៅក្រោមគម្រោងបែងចែកដីដើម្បី

សង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (LASED) និងសម្រាប់ គោលបំណងនៃធនាគារពិភពលោក (OP 4.10) ស្តីពីជនជាតិដើមភាគតិច មានតែជនជាតិដើមភាគតិច ដែលជាអ្នកស្រុកលើ "Khmer Loeu" រឺកុលសម្ព័ន្ធដែលរស់នៅតាមតំបន់ភ្នំ "hill tribes" ត្រូវបានគេចាត់ ទុកថាជាជនជាតិដើម។

៨. ផ្អែកលើរបាយការណ៍ដែលផលិតដោយគណៈកម្មាធិការនៃខេត្តស្ទឹងត្រែងឆ្នាំ ១៩៩៧ បានបង្ហាញថា នាពេលបច្ចុប្បន្នមានជនជាតិដើមភាគតិច ១៤ ក្រុមកំពុងរស់នៅក្នុងខេត្ត។ ក្រុមជនជាតិដើមភាគតិចទាំងនេះរួម មានៈ ខ្មែរ (៦៤ ២៧១ នាក់), ឡាវ (៤,៩២៨ នាក់), កាវែត (២ ០៦៤ នាក់), គួយ (១ ៥៨៨ នាក់), វៀតណាម (៦៧៤ នាក់), ចិន (៤៥៨ នាក់), ភ្នង (២៨៤ នាក់), លុន (៣៩៩ នាក់), ប្រាវ (៣៤៥ នាក់), គ្រឹង (២១០ នាក់), ចាម (៨៥ នាក់), ទុំពុន (១៨ នាក់), កាចុក (១៤ នាក់) និង ចារាយ (៥ នាក់)។ ក្នុងន័យទំនាក់ទំនងគ្នារបស់ក្រុមជនជាតិដើម ប្រជាជនកម្ពុជានៅក្នុងខេត្តស្ទឹងត្រែងតែងតែនិយមខ្លួនពួកគេថាជាអ្នកស្រុកលើ (មានន័យថាជាអ្នករស់នៅតំបន់ខ្ពង់រាប) ដែលបង្ហាញពីមនុស្សដែលរស់នៅតាមតំបន់កសិកម្ម និងដែលជាអ្នកដាំដុះស្រូវ និងដំណាំផ្សេងៗទៀតសម្រាប់ការប្រើប្រាស់នៅក្នុងគ្រួសាររបស់ពួកគេ រឺសម្រាប់លក់។ ក្រុមកុលសម្ពន្ធ រឺខ្មែរលើដែលគេស្គាល់ជាទូទៅថា បានប្រមូលផ្តុំរស់នៅតាម តំបន់ព្រៃភ្នំ ភាគឦសាន្តនៃប្រទេស។

## ២.២. និយតកម្ម និងគម្រោងស្របច្បាប់

៩. **រដ្ឋធម្មនុញ្ញ**នៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី ៣១.២ ចែងថា 'ពលរដ្ឋកម្ពុជាគួរមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ និងមានភាពរីករាយដូចគ្នាចំពោះសិទ្ធិ សេរីភាព និងករណីកិច្ច ដោយមិនគិតពីពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, ជំនឿ សាសនា, និន្នាការនយោបាយ, ដើមកំណើត, ស្ថានភាពសង្គម, ធនធាន និងតួនាទី '។ មាត្រាទី ៤៤ ធានានូវសិទ្ធិស្របច្បាប់ដើម្បីកាន់កាប់ដីដោយស្មើភាពគ្នាសម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូបៈ ពលរដ្ឋគ្រប់រូបជាបុគ្គល រឺជាសមូហភាពក្តីមានសិទ្ធិដើម្បីកាន់កាប់។ មានតែពលរដ្ឋកម្ពុជាស្របច្បាប់ដែលមានសញ្ជាតិខ្មែរទើបមានសិទ្ធិ ដើម្បីកាន់កាប់ដី។

១០. **ច្បាប់ស្តីពីដីធ្លី ឆ្នាំ ២០០១** ទទួលស្គាល់ពីសិទ្ធិនៃសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាដើម្បីធ្វើជាម្ចាស់អចលនៈទ្រព្យ ដីរបស់ពួកគេដែលមានឈ្មោះកម្មសិទ្ធិ។ មាត្រាទី ២៣ នៅក្នុងច្បាប់កំណត់ថា សហគមន៍ជនជាតិភាគតិចជាៈ

- ជាក្រុមនៃមនុស្សដែលបង្ហាញនូវសង្គម, វប្បធម៌ និងសេដ្ឋកិច្ចដែលមានលក្ខណៈសាមគ្គីភាព
- ជាអ្នកដែលអនុវត្តនូវរបៀបរស់នៅតាមបែបប្រពៃណី និង
- ជាអ្នកធ្វើកសិកម្មលើដីរបស់ពួកគេដោយយោងទៅលើទំលាប់នៃការប្រើប្រាស់រួមគ្នា

មាត្រាទី ២៥ នៅក្នុងច្បាប់កំណត់ពីដីសហគមន៍ជនជាតិដើមភាគតិចៈ ‘ ដីរបស់សហគមន៍ជនជាតិដើម គឺជាដីដែលពួកគេបានតាំងនៅ ហើយពួកគេអនុវត្តនូវការធ្វើកសិកម្មតាមបែបប្រពៃណី ’ និងដីទាំងនេះ ‘រួមទាំងដីដែលមិនបានធ្វើកសិកម្មពិតប្រាកដ ប៉ុន្តែក៏រួមបញ្ចូលផងដែរនូវដីកសិកម្មចល័ត (ពនាចរ) ដែលត្រូវបានតម្រូវដោយវិធីសាស្ត្រកសិកម្មដែលពួកគេអនុវត្តក្នុងពេលបច្ចុប្បន្ន ’ ។ មាត្រាទី ២៥ ក៏បានចែងថា ‘ការកំណត់ និងការវាស់វែងនៃព្រំប្រទល់អចលនៈទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិច គួរត្រូវបានកំណត់ដោយផ្អែកទៅលើស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ជនជាតិដើមភាគតិច និងការព្រមព្រៀងជាមួយអ្នកជិតខាងរបស់ពួកគេ’ ។ មាត្រាទី ២៦ បង្ហាញថា ‘ភាពជាម្ចាស់នៃអចលនៈទ្រព្យដែលបានរៀបរាប់នៅក្នុងមាត្រាទី ២៥ គឺត្រូវបានអនុញ្ញាតតាមរយៈរដ្ឋទៅដល់សហគមន៍ជនជាតិដើមភាគតិចថាជាសម្បត្តិរួម’ ។ ទ្រពសម្បត្តិសមូហភាពរួមបញ្ចូលទាំងនូវរាល់សិទ្ធិនានា និងការការពារនូវភាពជាម្ចាស់ដូចដែលត្រូវបានសប្បាយដោយម្ចាស់ឯកជននានា ។

១១. គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិដើម្បីប្រើប្រាស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ មេសារ ២០០៩ និងអនុក្រិត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានចុះហត្ថលេខានៅថ្ងៃទី ០៩ ខែមិថុនា ២០០៩ ដោយនាយករដ្ឋមន្ត្រី។ នយោបាយដីធ្លីនៅក្នុងឆ្នាំ ២០០៧ និងរំពឹងថាត្រូវបានគេ អនុម័តក្នុង ពេលឆាប់ៗនេះ។ គោលនយោបាយនេះទទួលយកជាមូលដ្ឋានគ្រឹះនូវការទទួលស្គាល់នៅក្នុងច្បាប់ស្តីពីដីធ្លីឆ្នាំ ២០០១ នៃសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចដើម្បីកាន់កាប់អចលនៈទ្រព្យជាទ្រព្យសម្បត្តិដែលមានឈ្មោះកម្មសិទ្ធិ។ គោលនយោបាយថ្លែងថាការចុះបញ្ជីនៃសហគមន៍ជនជាតិដើមភាគតិចជាទ្រព្យសម្បត្តិសមូហភាព គឺមានភាពខុសគ្នាពីការចុះបញ្ជីនៃដីដែលជាទ្រព្យសម្បត្តិដែលបានកាន់កាប់ដោយឯកជន ដោយហេតុថាការចុះបញ្ជីដីធ្លីនៃសហគមន៍ជនជាតិដើមភាគតិចគឺជាការចុះបញ្ជីនៃក្បាលដីទាំងអស់ដែលជាកម្មសិទ្ធិសហគមន៍ទាំងមូលដែលរួមទាំងដីឯកជន និងសារធារណៈរបស់រដ្ឋដោយស្របទៅតាមមាត្រាទី ២៥ មាត្រាទី ២៦ និងអនុក្រិត្យ ២២៩ នៃច្បាប់ដីធ្លី។ ក្បាលដីទាំងនេះមានភាពខុសគ្នាទាំងទំហំ និងអាចត្រូវបានតាំងនៅនៅតាមឃុំ រឺសង្កាត់ដូចគ្នា រឺផ្សេងគ្នា។ ដូចនេះ ការចុះបញ្ជីនៃក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចតម្រូវអោយបែងចែកនីតិវិធីដែលមាននៅក្នុងអនុក្រិត្យនៃការចុះបញ្ជីដីដែលមានលក្ខណៈជាប្រពន្ធ័ និងមិនទៀងទាត់។

១២. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២, (មាត្រាទី ១១, ១៥, ១៦ និង ៤០) ធានា និងទទួលស្គាល់នូវសិទ្ធិរបស់ជនជាតិដើមភាគតិចដើម្បីបន្តប្រើប្រាស់ និងប្រកបមុខរបរលើតំបន់ព្រៃឈើមួយចំនួនដែលក្រុមជនជាតិដើមភាគតិចទាំងនេះធ្លាប់ប្រើប្រាស់ជាប្រពៃណី និងអនុវត្តនូវរបៀបរស់នៅរបស់ពួកគេក្នុងន័យសប្បាយរីករាយលើផលប្រយោជន៍ពីព្រៃឈើ ។

## ផ្នែកទី III. បញ្ហានានា និងភាពទាក់ទងនៃគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិចនៅលើគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

### ៣.១. គោលនយោបាយប្រតិបត្តិ: ជនជាតិដើមភាគតិច (OP 4.10)

១៣. គោលនយោបាយប្រតិបត្តិរបសលធនាគារពិភពលោក ៤.១០ (ជនជាតិដើមភាគតិច) តម្រូវថាវិធានការផែនការពិសេស១ ត្រូវបានអភិវឌ្ឍន៍ដើម្បីការពារនូវផលប្រយោជន៍របស់ជនជាតិដើមភាគតិចជាមួយអត្តសញ្ញាណវប្បធម៌ និងសង្គមដែលខុសប្លែកគ្នាពីសង្គមទូទៅ ដែលអាចធ្វើអោយពួកគេងាយរងគ្រោះនៅក្នុងដំណើរការអភិវឌ្ឍន៍។

១៤. ដូចដែលបានបង្ហាញនៅក្នុងគោលនយោបាយប្រតិបត្តិ ៤.១០ ក្រុមជនជាតិដើមភាគតិចអាចត្រូវបានគេកំណត់នៅក្នុងតំបន់ដែលមានទីតាំងភូមិសាស្ត្រពិសេស តាមរយៈវត្តមាននៅក្នុងកម្រិតខុសៗគ្នានៃលក្ខណៈដូចខាងក្រោម:

ក. មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងធនធានធម្មជាតិ និងទឹកដីនៃបុព្វបុរសនៅក្នុងតំបន់ទាំងនេះ

ខ. ការកំណត់អត្តសញ្ញាណដោយខ្លួនឯង និងដោយអ្នកដ៏ទៃផ្សេងៗទៀតថាជាសមាជិកនៃក្រុមដែលមានវប្បធម៌ដាច់ដោយឡែកពីគេ

គ. មានភាសាជាជនជាតិដើមភាគតិច ដែលជាទូទៅមានភាពខុសគ្នាពីភាសាជាតិ

ឃ. បង្ហាញនូវស្ថាប័ននយោបាយ និងសង្គមដែលជាប្រពៃណី និង

១៥. តម្រូវឱ្យអ្នកខ្ចីរៀបចំដោយសេរី និងពិគ្រោះយោបល់ជាមួយក្រុមជនជាតិដើមជាមុនដែលមានសក្តានុពលរងផលប៉ះពាល់។ ដូចជាការរៀបចំជាមុនសម្រាប់ការអនុម័តគម្រោង ដំណើរការពិគ្រោះយោបល់នេះត្រូវតែបង្កើតជាគំរូនៃការគាំទ្រសហគមន៍ទូលំទូលាយសម្រាប់គម្រោង និងគោលបំណងរបស់វា។ នៅក្នុងបរិបទនៃគម្រោងនេះវាមានសារៈសំខាន់ដើម្បីកត់សំគាល់ថា OP 4.10 យោងទៅលើសហគមន៍ និងក្រុមសង្គម និងមិនមែនតែទៅលើបុគ្គល។ គោលបំណងចំបងនៃគោលនយោបាយប្រតិបត្តិ (OP 4.10) មាន:

- ធានាក្រុមទាំងនោះ គឺអាចមានឱកាសគ្រប់គ្រាន់ដើម្បីចូលរួមក្នុងការធ្វើផែនការដែលប៉ះពាល់ដល់ពួកគេ
- ធានាថាឱកាសនានាផ្តល់ដល់ក្រុមនោះ ជាមួយផលប្រយោជន៍ប្រពៃណីប្រកបដោយការពេញចិត្តហើយត្រូវបានយកចិត្តទុកដាក់ និង
- ធានាថាផលប៉ះពាល់គ្រប់គម្រោងទាំងអស់ដែលប៉ះពាល់ជាអវិជ្ជមានដល់ពួកគេត្រូវបានជៀសវាង រឺក៏ត្រូវបានសម្រាល និងធ្វើឱ្យមានផលប៉ះពាល់តិចតួច។

១៦. នៅក្នុងបរិបទនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ជនជាតិដើមភាគតិចនៅ ក្នុងខេត្តស្ទឹងត្រែង និងក្រចេះទំនងជាទទួលនូវផលប្រយោជន៍យូរអង្វែងតាមរយៈការគាំទ្រទៅលើសហគមន៍នេសាទ និងសកម្មភាពចិញ្ចឹមជីវិតសាកល្បងជាលក្ខណៈគ្រួសារ ប៉ុន្តែពួកគេអាចទទួលប៉ះពាល់ជាអវិជ្ជមានតាមរយៈសកម្មភាពការកសាងសមត្ថភាពនៃភ្នាក់ងារជលផលនៅតាមមូលដ្ឋាន និងថ្នាក់ជាតិ ដោយរួមទាំងការតាមដាននៃផលចាប់។ សំរាប់គម្រោងគ្រប់គ្រង ធនធានទឹកចម្រុះទន្លេមេគង្គ ដូចនេះគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិចបានផ្តោតទៅលើកិច្ចពិគ្រោះយោបល់ដើម្បីប្រាកដថាជនជាតិដើមភាគតិចទាំងនោះមានសម្លេងចំពោះភាពទាក់ទិនរបស់ពួកគេ និងបានយល់ព្រមទទួលផលប្រយោជន៍ និងចូលរួមពីគម្រោង។ ដូចនេះដំណើរការឆ្លុះបញ្ចាំង ការពិគ្រោះយោបល់ជាមួយសហគមន៍ ជនជាតិភាគតិចបានប្រព្រឹត្តទៅរហូតដល់ថ្ងៃអនុវត្តដោយសេរីជាមុនការពិគ្រោះយោបល់នានាដែលបានបង្ហាញ ទៅដល់ " ការគាំទ្រសហគមន៍ "។

## ៣.២. ការឆ្លុះបញ្ចាំងសម្រាប់ជនជាតិដើមភាគតិច និងផលប៉ះពាល់របស់គម្រោងគ្រប់គ្រងធនធានធម្មជាតិ

១៧. ការរៀបចំគម្រោងត្រូវបានរៀបចំដើម្បីរួមបញ្ចូលនូវសេចក្តីត្រូវការក្នុងការលើកកម្ពស់ (មានអត្ថន័យ) ការចូលរួមដោយអ្នកក្រីក្រ និងផ្នែកដែលមិនទទួលបានផលប្រយោជន៍នៃសង្គម តាមរយៈការបង្កើតដំណើរការរៀបចំផែនការនៃការចូលរួម។ ការពិគ្រោះយោបល់ជាពិសេសក៏ត្រូវបានធ្វើឡើងផងដែរកំលុងពេលនៃការបញ្ចប់នៃការសិក្សាសង្គម និងបរិស្ថានលើកតំបូង និងការរៀបចំវិធីសាស្រ្តសុវត្ថិភាព(គម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច) នៃគម្រោង។ ដូចនេះដើម្បីធានាថាក្រុមជាជាតិដើមភាគតិចគឺ (១) ត្រូវបានពិគ្រោះយោបល់នូវបញ្ហាទាក់ទងទៅនឹងការវិនិយោគ (២). ឱកាសដែលបានផ្តល់ឱ្យសម្រាប់ការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងទៅនឹងងការវិនិយោគ និងទី (៣). ឱកាសដែលបានផ្តល់ឱ្យសម្រាប់ការ ចូលរួមនៅក្នុងសកម្មភាពគម្រោងគួរជាទី ប្រាថ្នារបស់ពួកគេ (គឺជាការចង់បានរបស់ពួកគេ)។ ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងតាមរយៈភ្នាក់ងារនានាដែលបានជួយ តាមរយៈអ្នកជំនាញក្រុមទីប្រឹក្សាជាតិ និងអន្តរជាតិ និងការចូលរួមពីអ្នកជំនាញពីធនាគារពិភពលោក។ ដំណើរការពិគ្រោះយោបល់ដែលបានធ្វើឡើងមានលទ្ធផលទៅលើការបង្កើតនៃជំរឿនសហគមន៍ និងគាំទ្រដល់គម្រោង។ របាយការណ៏ពិគ្រោះយោបល់ត្រូវបានរៀបចំ ហើយវានឹងអាចមានភាពងាយស្រួលដល់ការបិទប្រកាសជា សាធារណៈនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

១៨. ការសិក្សាសង្គម និងបរិស្ថានតំបូងស្នើថាជនជាតិភាគតិចនៅតាមតំបន់នៃគម្រោង (ខេត្តស្ទឹងត្រែង និងក្រចេះ) គួរទទួលនូវផលប៉ះពាល់ជាវិជ្ជមាន ប៉ុន្តែអាចត្រូវបានប៉ះពាល់តាមរយៈការកំណត់ធនធានប្រើប្រាស់

និងការពិគ្រោះយោបល់បន្ទាប់ វិធីសាស្ត្រខាងក្រោម ជាគោលការណ៍ តាមរយៈសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងក្នុងដែលមានសកម្មភាពនៅក្នុងតំបន់នៃគម្រោង។

- ទី១ ការគ្រប់គ្រងជលផលដែលប្រសើរគួរផ្តល់ផលប្រយោជន៍ទៅដល់សហគមន៍មូលដ្ឋានរយៈពេលយូរ ដោយបង្កើតការគ្រប់គ្រងជលផលដោយនិរន្តរភាព។
- ទី ២ ផែនការគប់គ្រងជលផល គួរត្រូវបានអភិវឌ្ឍន៍តាមរយៈការចូលរួមយ៉ាងពេញលេញ និងភាពជាម្ចាស់ទៅលើសហគមន៍ រួមទាំងជនជាតិដើមភាគតិច និង
- ទី ៣ គម្រោងគួរផ្តល់នូវសកម្មភាពចិញ្ចឹមជីវិតសាកល្បងជាលក្ខណៈគ្រួសារ (ដែលនឹងត្រូវជ្រើសរើសតាមរយៈ ការរៀបចំផែនការដោយមានការចូលរួមជាមួយប្រជាជនដែលទទួលផលប៉ះពាល់) ដើម្បីសម្រាលនូវផលប៉ះពាល់ជាអវិជ្ជមានទៅលើជីវភាពរស់នៅរបស់ពួកគេ។

១៩. ការបញ្ចប់នៃវិនិយោគដែលដាក់ស៊ុំនឹងត្រូវបានអនុវត្តកំលុងពេលនៃដំណើរការវាយតម្លៃសង្គម និងការអនុវត្ត ហើយនឹងត្រូវអនុវត្តដើម្បីកំណត់ពីព្រំដែន និងដើមហេតុនៃផលប៉ះពាល់ទៅលើជនជាតិដើមភាគតិចក្នុងចំណោមនៃប្រជាជនដែលបានរងនូវផលប៉ះពាល់។ តាមរយៈនៃការប្រមូលទិន្នន័យលេខ និងអក្សរនៅតាមតំបន់របស់គម្រោងតាមរយៈបច្ចេកទេសនៃការវាយតម្លៃដោយមានការចូលរួម ប្រវត្តិសេដ្ឋកិច្ច និងសង្គមសំខាន់ៗនៃប្រជាជនដែលទទួលផលប្រយោជន៍ រឺប្រជាជនដែលទទួលផលប៉ះពាល់ពីគម្រោងត្រូវបានអភិវឌ្ឍន៍។ ការវិនិយោគជាអាទិភាពដែលត្រូវបានផ្តល់ហិរញ្ញវត្ថុនៅក្រោមគម្រោង នឹងស្របទៅនឹងនីតិវិធី និងគោលការណ៍នានាដែលបានរៀបរាប់នៅក្នុងអនុផ្នែក ៣.៣ ខាងក្រោម។ នីតិវិធី និងយន្តការីសារទុក្ខត្រូវបានអភិវឌ្ឍន៍ គ្រប់គ្រង និងតាមដាន។

## ៣.៣. នីតិវិធី និងគោលការណ៍នានាដែលបានអនុវត្តនៅក្នុងគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

២០. ផ្នែកគ្រប់គ្រងគម្រោងនឹងធានាពីសេរីភាព អាទិភាព និងត្រូវបានបង្ហាញតាមរយៈកាធ្វើពិគ្រោះយោបល់ជាភាសាដែលគេប្រើ និងទីតាំងសមស្របនូវសក្តានុពលផលប៉ះពាល់ទៅលើជនជាតិដើមភាគតិច។ ទស្សនៈនានានៃក្រុមជនជាតិដើមភាគតិចត្រូវបានយកចិត្តទុកដាក់ក្នុងអំឡុងពេលនៃការអនុវត្ត និងរៀបចំនៃការវិនិយោគគោរពនូវការអនុវត្តន៍នានាក្នុងពេលបច្ចុប្បន្នរបស់ពួកគេ ជំនឿ និងការនិយមវប្បធម៌។ លទ្ធផលនៃការពិគ្រោះយោបល់នឹងត្រូវបានចងក្រងជាឯកសារទៅក្នុងឯកសាររបស់គម្រោង។

២១. កំលុងពេល ៣ ខែនៃការអនុវត្តគម្រោង ផ្នែកគ្រប់គ្រង/អនុវត្តគម្រោងនឹងអនុវត្តការសិក្សាអោយបានស៊ីជម្រៅថែមទៀតទៅលើមូលហេតុ និងការពង្រីកនៃផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានទៅលើជនជាតិដើមភាគតិច និងកំណត់នូវការវិនិយោគជាអាទិភាពដូចដែលបានរៀបរាប់នៅក្នុងវគ្គទី ១៩ ខាងលើ។ ប្រសិនបើការវាយតម្លៃសង្គមបង្ហាញថាគម្រោងដែលបានដាក់សុំមានផលប៉ះពាល់ទៅដល់ជនជាតិដើមភាគតិច នោះគម្រោងអភិវឌ្ឍន៍នឹងអនុវត្តតាមគោលការណ៍ណែនាំដែលបានផ្តល់នៅក្នុងផ្នែកទី IV។ គម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិចនឹងត្រូវបានដាក់ស្នើទៅធនាគារពិភពលោកដើម្បីពិភាក្សាមុនពេលគម្រោងចាប់ផ្តើមអនុវត្ត។ ប្រសិនបើក្រុមជនជាតិដើមភាគតិចជំទាស់គម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច នោះការវិនិយោគមិនត្រូវបានអនុម័ត។

២២. ប្រសិនបើក្រុមជនជាតិដើមភាគតិចត្រូវបានគេសម្រេចថា ការវិនិយោគនឹងមានសារៈប្រយោជន៍ដល់ពួកគេ និងផលប៉ះពាល់ជាអវិជ្ជមាននានាត្រូវបានសម្រាល នោះគម្រោងការដើម្បីជួយដល់ពួកគេនឹងត្រូវបានអភិវឌ្ឍន៍ដោយយោងទៅលើការពិគ្រោះយោបល់ជាមួយក្រុមជនជាតិដើមភាគតិចទាំងនោះ និងតំណាងអង្គការសង្គមស៊ីវិលនានា (NGO)។ សហគមន៍គួរត្រូវបានពិគ្រោះយោបល់ផងដែរដើម្បីធានាថាវប្បធម៌ និងសិទ្ធិរបស់ពួកគេត្រូវបានគោរព។ ជំនួយការអាចរួមបញ្ចូលផងដែរនូវការពង្រឹងស្ថាប័ន និងពង្រឹងសមត្ថភាពនៃភូមិជនជាតិភាគតិចនានា និងក្រុមសហគមន៍មួយចំនួនដោយធ្វើការជាមួយការវិនិយោគទុន។

២៣. វគ្គបណ្តុះបណ្តាលនានាទៅដល់អ្នកអនុវត្ត និងភ្នាក់ងារនានានឹងត្រូវបានផ្តល់អោយ។ ភ្នាក់ងាររដ្ឋាភិបាលទទួលខុសត្រូវដើម្បីពិនិត្យពិច័យលើបញ្ហាជនជាតិដើមភាគតិច និងសង្គមស៊ីវិលដែលមានសកម្មភាពនៅតាមតំបន់នឹងត្រូវបានអញ្ជើញចូលរួមជាអ្នកសំខាន់ដើម្បីផ្តល់នូវការបណ្តុះបណ្តាល។

## ៣.៤. ការរាយការណ៍, ចងក្រងឯកសារ និងការតាមដាន សំរាប់គម្រោងគ្រប់គ្រងធនធានទឹក ចម្រុះនន្លេមេគង

២៤. ដំណើរនៃការពិគ្រោះយោបល់ ការវាយតម្លៃសង្គម និងការអង្កេតដែលបានលើកឡើង នឹងផ្តល់នូវព័ត៌មានបង្គោលស្តីពីទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងបច្ចេកទេសនៃការវិនិយោគនីមួយៗ។ ទាំងនេះរួមមានផងដែរនូវការចូលរួមធ្វើផែនទីសហគមន៍ទៅកាន់ផ្លូវលំ និងសេវាកម្មសំខាន់ផ្សេងៗទៀត។ ប្រសិនបើការវាយតម្លៃសង្គមបង្ហាញថាមិនមានសហគមន៍ជនជាតិដើមភាគតិចរស់នៅក្នុងតំបន់សិក្សា មិនមានសកម្មភាពសិក្សាផ្សេងៗទៀតចាំបាច់នោះទេ។ ប្រសិនបើការវាយតម្លៃសង្គមបង្ហាញថា មានសក្តានុពលនៃបញ្ហាសង្គមនានាដែលបណ្តាលមកពីក្រុមជនជាតិដើមភាគតិចនៅក្នុងគម្រោង នោះនឹងមានវិធានការដាក់លាក់មួយដើម្បីពិគ្រោះយោបល់ជាមួយនឹងការផ្តល់ឱកាសដល់ក្រុមជនជាតិដើមភាគតិចក្នុងការចូលរួមធ្វើការសម្រេចចិត្តទាក់ទិនទៅនឹងការវិនិយោគ

ដែលពួក គេប្រាថ្នាចង់បាន។ ដំណើរការនៃការវាយតម្លៃសង្គមខ្លួនឯង ជាវិធីសាស្ត្រមួយដែលត្រូវបានធ្វើឡើងតាមរយៈ ការពិគ្រោះយោបល់។ ទោះជាយ៉ាងណា ពួកគេអាចត្រូវបានអនុវត្តដូចជាការធ្វើលំហាត់ដាច់ដោយឡែកពីគ្នា។

២៥. ក្រៅពីការប្រុងប្រយ័ត្នយ៉ាងជាក់លាក់លើបញ្ហានានារបស់ក្រុមជនជាតិភាគតិចក្នុងការតាមដាន និងគ្រប់គ្រងផ្នែកគ្រប់គ្រងគម្រោង នឹងដាក់បញ្ចូលបញ្ហាទាំងនេះទៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់ពួកគេ។ បេសកកម្ម IDA នឹងយកចិត្តទុកដាក់ ដើម្បីធានាថាផលប៉ះពាល់នៃការវិនិយោគទៅលើក្រុមជនជាតិដើមភាគតិចទទួលបានផលប្រយោជន៍ សមរម្យ និងសម្រាលទៅលើផលប៉ះពាល់ជាអវិជ្ជមានលើពួកគេ។

## ផ្នែកទី VI. គោលការណ៍បច្ចេកទេសសំរាប់គម្រោងពិគ្រោះយោបល់លើបញ្ហានានារបស់ក្រុមជនជាតិភាគតិចដែលទទួលផលប៉ះពាល់ពីគម្រោង (M- IWRMP)

២៦. គម្រោងពិគ្រោះយោបល់មានគោលបំណងដើម្បីធានាថាក្រុមជនជាតិដើមភាគតិចត្រូវបានគេឱ្យ ដំណឹង, ពិគ្រោះយោបល់បានល្អដើម្បីចូលរួមនៅក្នុងការវិនិយោគ ដែលត្រូវបានគាំទ្រដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ។ ការចូលរួមរបស់ពួកគេអាចផ្តល់ដល់គេនូវផលប្រយោជន៍យ៉ាងទៀងទាត់ រឺក៏ការពារពួកគេមិនឱ្យទទួលនូវផលប៉ះពាល់ជា អវិជ្ជមាននានានៃការវិនិយោគដែលគាំទ្រថវិការដោយគម្រោង។ ដំណើរការ/លក្ខណៈនៃគម្រោងពិគ្រោះយោបល់ រួមទាំងដំណើរការឆ្លុះបញ្ចាំងចំបង១ បន្ទាប់មកការវាយតម្លៃលើផលប៉ះពាល់សង្គម និងបរិស្ថានកំណត់ពីកិរិត និងមូលហេតុនៃផលប៉ះពាល់នៃអនុគម្រោងនីមួយៗដែលត្រូវបានគាំទ្រថវិការដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ និងផែនការសកម្មភាពនឹងត្រូវបានអភិវឌ្ឍន៍ប្រសិនត្រូវបានអនុញ្ញាត។ ការពិគ្រោះយោបល់ដោយមានការចូលរួមពីក្រុមជនជាតិដើមភាគតិច និងអ្នកដឹកនាំរបស់ពួកគេ ព្រមទាំងអាជ្ញាធរមូលដ្ឋាន គឺជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិច និងគួរត្រូវបានរៀបចំជាមួយនៅក្នុងរបាយការណ៍ស្តីពីលទ្ធភាពតំបូងដែលអាចដំណើរការបាននៃគម្រោង។ សមាសធាតុសំខាន់ៗនៃគោលការណ៍ណែនាំដែលបានពិភាក្សាជាលំអិតមាននៅក្នុងអនុផ្នែក ៤.១ - ៤.៨ ខាងក្រោមៈ

២៧. ការបណ្តុះបណ្តាលបន្តបន្ទាប់ទៅដល់អ្នកអនុវត្ត និងភ្នាក់ងារអនុវត្ត និងរៀបចំនៅតាមមូលដ្ឋានត្រូវបានផ្តល់

### ៤. ១. ការបង្ហាញសំខាន់ៗ

២៨. ដើម្បីកំណត់ ប្រសិនបើជនជាតិដើមភាគតិចមាននៅក្នុងទីតាំងបែគម្រោង ដំណើការឆ្លុះបញ្ចាំងតំបូងអាចរួមបញ្ចូលទាំងការពិគ្រោះយោបល់ និងការវាយតម្លៃសង្គមដែលផ្តល់នូវព័តិមានមូលដ្ឋានពីស្តីពីសង្គម សេដ្ឋកិច្ច និងទិដ្ឋភាពបច្ចេកទេសនៃការវិនិយោគនីមួយៗ។ នេះរួមទាំងការកំណត់នូវការចូលរួមនៃសហគមន៍ទៅលើការ

កសាងផ្លូវលំ និងសេវាកម្មសំខាន់ផ្សេងទៀត។ ប្រសិនបើការវាយតម្លៃសង្គមបង្ហាញថាមិនមានសហគន៏ជនជាតិដើមភាគតិចរស់នៅតាមតំបន់របស់គម្រោង នោះមិនចាំបាច់មានការសិក្សានោះទេ។ ប្រសិនបើការវាយតម្លៃសង្គមបង្ហាញថាមានបញ្ហាសង្គមទៅលើសហគន៏ជនជាតិដើមភាគតិច ដោយហេតុមកពីការវិនិយោគ នោះអ្នកទទួលខុសត្រូវគម្រោងនឹងចាត់វិធានការជាក់លាក់មួយដើម្បីពិគ្រោះយោបល់ជាមួយ និងផ្តល់ឱកាសដល់ជនជាតិដើមភាគតិចដើម្បីចូលរួមសំរេចចិត្តទាក់ទងទៅនឹងការវិនិយោគ។ ដំណើរការវាយតម្លៃសង្គមតែងតែជាវិធីសាស្រ្តមួយដែលត្រូវបានគេអនុវត្ត។

២៩. រាល់តំបន់វិនិយោគដែលមានសហគមន៏ជនជាតិដើមភាគតិច និងជាសមាជិកសម្រាប់ការគាំទ្រនៃការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនឹងត្រូវបានទស្សនៈកិច្ច (ខណៈនៃកិច្ចពិគ្រោះយោបល់លើកដំបូងជាមួយសហគមន៏) តាមរយៈនៃការគាំទ្រដោយគម្រោង និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ ដោយរួមទាំងបុគ្គលិកដែលមានបទពិសោធន៏ រឺបណ្តុះបណ្តាលបច្ចេកទេសសង្គមល្អ។ អាទិភាពទៅនឹងការទស្សនៈកិច្ច ម្ចាស់គម្រោង នឹងផ្ញើសេចក្តីប្រកាសដល់សហគមន៏នានា ដើម្បីប្រាប់អ្នកដឹកនាំរបស់ពួកគេថាពួកគេនឹងត្រូវបានសាកសួរសុខទុក្ខដោយអ្នកផ្តល់គម្រោង និងអាជ្ញធរហើយការពិគ្រោះយោបល់នឹងត្រូវបានធ្វើឡើងស្តីពីការវិនិយោគ។ ការប្រកាសនឹងស្នើសុំសហគមន៏អញ្ជើញទៅក្នុងតំណាងនៃកិច្ចប្រជុំនៃកសិករ អ្នកនេសាទ សមាគមស្រ្តី និងប្រធានភូមិ ដើម្បីធ្វើការពិភាក្សាស្តីពីការវិនិយោគ។ ក្នុងពេលនៃដំណើរទស្សនៈកិច្ច ប្រធានសហគមន៏ និងអ្នកចូលរួមផ្សេងៗទៀតនឹងបង្ហាញនូវទស្សនៈរបស់ពួកគេដែលទាក់ទងទៅនឹងការវិនិយោគ។

៣០. ដំណើរទស្សនៈកិច្ចនេះ មន្ត្រីដែលមានបទពិសោធន៏ និងបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រសង្គម នឹងទទួលយកនូវការបង្ហាញសំខាន់ៗសម្រាប់ក្រុមជនជាតិដើមភាគតិច ជាមួយនឹងការជួយជ្រោមជ្រែងពីអ្នកដឹកនាំ និងអាជ្ញាធរមូលដ្ឋាន។ ការបង្ហាញនឹងពិនិត្យដូចខាងក្រោម:

(ក). ឈ្មោះនៃក្រុមជនជាតិដើមភាគតិចនៅក្នុងភូមិដែលសិក្សា

(ខ). ចំនួនសរុបនៃក្រុមជនជាតិដើមភាគតិចនៅក្នុងភូមិដែលសិក្សា

(គ). ភាគរយនៃចំនួនជនជាតិដើមភាគតិចនៅក្នុងភូមិដែលសិក្សា

(ឃ). ចំនួន និងភាគរយនៃគ្រួសារជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលបានរៀបរាប់របស់ការវិនិយោគដែលបានស្នើ។ (តំបន់ដែលមានទទួលរងនូវឥទ្ធិពល គួរសរុបនូវតំបន់ទាំងអស់ដែលផលប្រយោជន៏នានាទាក់ទងនឹងការវិនិយោគ និងផលប៉ះពាល់ជាវិជ្ជមានទំនងជាទាក់ទងគ្នា)។

៣.១ ប្រសិនបើលទ្ធផលបង្ហាញថា មានសហគមន៏ជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលមានឥទ្ធិពលលើរបស់គម្រោងវិនិយោគដែលបានស្នើ ការវាយតម្លៃសង្គមនឹងត្រូវបានគ្រោងធ្វើសម្រាប់តំបន់ទាំងនោះ។

## ៤. ២. ការវាយតម្លៃសង្គម

៣២. ការវាយតម្លៃសង្គមនឹងត្រូវបានធ្វើឡើងតាមរយៈអ្នកបច្ចេកទេសសង្គមដែលមានបទពិសោធន៍ (វិទីប្រឹក្សាបច្ចេកទេស) ដែលមានការយល់ដឹងនូវវប្បធម៌នៃក្រុមជនជាតិភាគតិចដែលពាក់ព័ន្ធ។ ការវាយតម្លៃសេដ្ឋកិច្ចសង្គមនឹងប្រមូលព័ត៌មានពាក់ព័ន្ធសំខាន់ៗដូចខាងក្រោម: ស្ថិតិនៃចំនួន ប្រជាជន សង្គម វប្បធម៌ និងស្ថានភាពសេដ្ឋកិច្ច និងសង្គម វប្បធម៌ និងផលប៉ះពាល់សេដ្ឋកិច្ចដែលមានលក្ខណៈ ជាវិជ្ជមាន និងអវិជ្ជមាន។

៣៣. សេរីភាព អាទិភាព និងកិច្ចពិគ្រោះយោបល់នឹងត្រូវបានអនុវត្តតាមរយៈការជួមប្រជុំបន្តរបន្ទាប់ រួមទាំងការប្រជុំដែលមានលក្ខណៈដោយក្រុមឡែកៗ ប្រធានភូមិជនជាតិដើមភាគតិច ជនជាតិដើមជាបុរស និងស្ត្រីជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ដែលទទួលរងឥទ្ធិពលរបស់ការងារនៃអនុគម្រោង។ រាល់ការពិភាក្សា នឹងត្រូវបានចងក្រងជាឯកសារនៅតាមទីតាំងដែលងាយរក។ រាល់ការពិភាក្សានឹងត្រូវបានធ្វើឡើងដោយប្រើប្រាស់ភាសានៅតាមមូលដ្ឋាន។ ការពិភាក្សានានានឹងផ្តោតទៅលើផលប៉ះពាល់នៃការវិនិយោគជាវិជ្ជមាន និងអវិជ្ជមាន និងផ្តល់អនុសាសន៍សម្រាប់ការរៀបចំនៃការវិនិយោគ។ ប្រសិនបើការវាយតម្លៃសង្គមបង្ហាញថាផលប៉ះពាល់នៃគម្រោងវិនិយោគដែលស្ទើនឹងមានផលប៉ះពាល់យ៉ាងខ្លាំង រឺក៏សហគមន៍ជនជាតិដើមភាគតិចច្រានចោលនូវគម្រោង នោះគម្រោងវិនិយោគមិនត្រូវបានអនុមត័ (ដូចនេះមិនមានសកម្មភាពចាំបាច់បន្តទៀតនោះទេ)។ ប្រសិនបើក្រុមជនជាតិដើមភាគតិចគាំទ្រការ អនុវត្តអនុគម្រោងក្រុមជនជាតិដើមភាគតិចនឹងត្រូវបានអភិវឌ្ឍន៍ ដើម្បីធានាថាក្រុមជនជាតិដើមភាគតិចទទួលនូវឱកាសសមរម្យតាមបែបប្រពៃណីពីសកម្មភាពវិនិយោគ និង ដើម្បីបង្ហាញពីភាពពាក់ព័ន្ធនានា រឺផលប៉ះពាល់ជាអវិជ្ជមានទាក់ទងទៅនឹងការវិនិយោគ។

## ៤.៣. ផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិច

៣៤. ផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិចនឹងរៀបរាប់នូវលទ្ធផល និងដំណើរការពិភាក្សា និងការយកចិត្តទុកដាក់រៀបចំជាបន្តបន្ទាប់ដើម្បីធានាថាក្រុមជនជាតិដើមភាគតិចទទួលផលប្រយោជន៍ពីសកម្មភាពវិនិយោគ និងវិធានការនោះត្រូវបានផ្តល់ឱ្យដើម្បីសម្រាលដល់ផលប៉ះពាលជាអវិជ្ជមានលើពួកគេ។ ផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិចរួមមាន:

១. គម្រោងការស្របច្បាប់
២. ទិន្នន័យមូលដ្ឋាន
៣. ព័ត៌មានស្តីពីសិទ្ធិកាន់កាប់ដី
៤. ព័ត៌មានស្តីពីការពិគ្រោះយោបល់ និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន

៥. ការកំណត់នូវបច្ចេកទេសនៃសកម្មភាពសម្រាលវិការអភិវឌ្ឍន៍នានា

៦. ការរៀបចំនៃស្ថាប័ន

៧. ផែនការអនុវត្ត

៨. តាមដាន និងវាយតម្លៃ និង

៩. ការចំណាយ និងផែនការហិរញ្ញវត្ថុ

## ៤.៤. ការរៀបចំនូវការអនុវត្ត

៣៥. ផ្នែកគ្រប់គ្រងគម្រោងនឹងទទួលខុសត្រូវសម្រាប់គម្រោងបណ្ដុះបណ្ដាលរៀងៗខ្លួន រឺអាជ្ញាធរអនុវត្ត ការងារនៃការពិភាក្សា ការវាយតម្លៃផលប៉ះពាល់សង្គម វិភាគ និងរៀបចំផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិច (EGDPs) ។

៣៦. អ្នកផ្ដល់គម្រោងនៃការវិនិយោគមួយៗ និងអាជ្ញាធរមូលដ្ឋានគឺទទួលខុសត្រូវសម្រាប់ការអនុវត្ត ផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិច ( រៀបចំមន្ត្រី និងថវិការឱ្យបានគ្រប់គ្រាន់) ។

## ៤.៥. ការតាមដាន

៣៧. ការអនុវត្តនៃផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិចនឹងត្រូវបានតាមដាន និងគ្រប់គ្រងជាប្រចាំដោយផ្នែកគ្រប់គ្រងគម្រោង ។ ការផ្ដល់អនុសាសន៍ និងការរកឃើញ នឹងត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ប្រចាំត្រីមាស និងត្រូវបានផ្ដល់ទៅដល់ IDA ។

៣៨. ការវិនិយោគទាក់ទងជាមួយផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិច នឹងត្រូវបានផ្អែកទៅលើការតាមដានដោយទីប្រឹក្សាបច្ចេកទេសឯករាជ្យ ។ ភ្នាក់ងារតាមដានមកពីក្រៅ រឺទីប្រឹក្សាបច្ចេកទេសគួរត្រូវបានរកដែលស្ថិតនៅក្រោមកិច្ចសន្យាដែលគុណភាពនៃរបាយការណ៍ វិធីសាស្ត្រនៃការធ្វើសម្ភាសន៍ ការប្រមូលទិន្នន័យ និងការតាមដានជាក់លាក់ និងញឹកញាប់ ។ របាយការណ៍តាមដានគួរត្រូវបានរក្សាទុកដោយផ្នែកគ្រប់គ្រងគម្រោង និងផ្ដល់ភាពងាយស្រួលដល់ក្រុមការងារធនាគារពិភពលោក ។

## ៤.៦. ផែនការ

៣៩. ផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិចគួរមានផែនការអនុវត្តដែលត្រូវបានសម្របសម្រួលជាមួយការអនុវត្តវិនិយោគ។ ភាពត្រឹមត្រូវ ការប្រជុំជាក្រុម និងការវាយតម្លៃសង្គមគួរត្រូវបានអនុវត្តមុនការរៀបចំវិនិយោគត្រូវបានបញ្ចប់ ។ ការតាមដានគួរត្រូវបានអនុវត្តក្នុងកំឡុងពេលដែលបានផ្ដល់អនុសាសន៍ និងបន្ទាប់ការងារសង្គមស៊ីវិល ។

### ៤.៧. ថវិកា

៤០. ផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិចនឹងរួមបញ្ចូលព័ត៌មានលំអិតស្តីពីការចំណាយទៅលើវិធីសាស្ត្រនៃការសម្រាល និងការឱ្យសិទ្ធិស្ការឡើងវិញសម្រាប់ក្រុមជនជាតិដើមភាគតិចនៅក្នុងតំបន់វិនិយោគ/សិក្សា។ ប្រភពនានានៃថវិកាសម្រាប់ផែនការហិរញ្ញវត្ថុ និងសកម្មភាពផ្សេងៗទៀតនឹងត្រូវបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងតារាងខ្ទង់ចំណាយ។

### ៤.៨. ការធ្វើរបាយការណ៍/ឯកសារ

៤១. ប្រសិនបើគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិចត្រូវបានតម្រូវអោយ អ្នកកាន់អនុគម្រោងនឹងរៀបចំ និងដាក់ជូនផែនការអភិវឌ្ឍន៍របស់ក្រុមជនជាតិដើមភាគតិចទៅកាន់ធនាគារពិភពលោក ដើម្បីបញ្ជាក់មុនពេលចាប់ផ្តើមអនុវត្តគម្រោង។ ដូចដែលបានរៀបរាប់ខាងលើ របាយការប្រចាំត្រីមាស និងរបាយការណ៍តាមដាននឹងត្រូវបានរៀបចំតាមរយៈភ្នាក់ងារតាមដាន និងផ្នែកគ្រប់គ្រងគម្រោង ហើយនឹងត្រូវរក្សាទុកនៅផ្នែកគ្រប់គ្រងគម្រោង និងធ្វើអោយងាយស្រួលដល់ធនាគារពិភពលោកធ្វើការសង្ខេប។

### ៤.៩. យន្តការសារទុក្ខ និងតម្លាភាព

៤២. យន្តការសារទុក្ខដែលស្ថិតនៅក្រោមគម្រោងនឹងត្រូវបានរៀបជាថ្នាក់ៗៈ ផ្នែកខាងក្នុងនៃសហគមន៍ដែលបានពាក់ព័ន្ធ និងផ្នែកផ្សេងៗទៀត ការពាក់ព័ន្ធទៅនឹងការសម្របសម្រួលខាងក្រៅ/អ្នកទី ៣។ មុនការចាប់ផ្តើមនៃការអនុវត្តគម្រោង គណៈកម្មការសារទុក្ខនឹងត្រូវបានបង្កើតពីតាមភូមិនានាទៅដល់ខេត្ត ដែលបានកសាងទៅលើរចនាសម្ព័ន្ធមាននាយកដ្ឋានពាក់ព័ន្ធស្រាប់ អង្គការមួយចំនួន តំណាងក្រុមជនជាតិដើមភាគតិច និងតំណាងស្ត្រី។ នៅថ្នាក់ភូមិ រចនាសម្ព័ន្ធមានឈ្មោះថា គណៈកម្មការសម្របសម្រួលភូមិដែលដឹកនាំ ដោយចាស់ព្រឹទ្ធាចារ្យ រឺមេដឹកនាំកុលសម្ព័ន្ធដែលទទួលស្គាល់ដោយសហគមន៍នៅមូលដ្ឋាន ជាពិសេសក្រុមជនជាតិភាគតិច។ គម្រោងនឹងផ្តល់ការគាំទ្រ និងការបណ្តុះបណ្តាលដើម្បីពង្រឹងរចនាសម្ព័ន្ធដែលមានស្រាប់សំរាប់ការដោះស្រាយប្រកបដោយប្រសិទ្ធិភាពជាមួយសារទុក្ខដែលអាចមានទៅលើប្រជាជនដែលទទួលរងផលប៉ះពាល់ក្នុង កំលុងពេលនៃការអនុវត្តគម្រោងតាំងលំនៅដ្ឋានឡើងវិញ។

៤៣. ប្រជាជនដែលទទួលរងផលប៉ះពាល់ ប្រសិនបើមិនមានការពេញចិត្ត រឺមិនមានភាពច្បាស់លាស់អំពីសំណងនិងការអនុវត្តគម្រោងតាំងលំនៅដ្ឋានឡើងវិញ ដែលអាចលើកឡើងតាមរយៈការតវ៉ានានារបស់ពួកគេទៅដល់គណៈកម្មការ។ ការជំទាស់អាចត្រូវបានធ្វើឡើងដោយផ្ទាល់ រឺតាមរយៈនៃការសរសេរជាមួយការជំនួយពី

គណៈកម្មការភូមិដែលគួរផ្តល់ការឆ្លើយតបចំពោះការតវ៉ាក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីទទួលការតវ៉ា។ ប្រសិនបើការតវ៉ាមិនត្រូវបានពេញចិត្តជាមួយការសំរេចចិត្តដែលបានធ្វើថ្នាក់ភូមិ ពួកគេអាចដាក់ស្នើទៅគណៈ-កម្មការថ្នាក់ស្រុក ជាមួយការគាំទ្រពីផ្នែកអនុវត្តគម្រោង។ ក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីទទួលការតវ៉ាគណៈ-កម្មការថ្នាក់ស្រុកគួរធ្វើការសំរេចចិត្ត និងផ្តល់ការឆ្លើយតបចំពោះការតវ៉ា។ ការតវ៉ាអាចត្រូវបានត្រូវបានធ្វើឡើងនៅតុលាការខេត្តដែលកាត់ក្តីគួរត្រូវបញ្ចប់។ រាល់សារទុក្ខ និងការតវ៉ានឹងត្រូវបានបំពេញ និងរៀបចំយ៉ាងត្រឹមត្រូវដោយគណៈកម្មការភូមិ និងស្រុក ក៏ដូចជាផ្នែកអនុវត្តគម្រោងដែលបានលើកឡើងតាមរយៈការពិគ្រោះយោបល់ក្នុងលក្ខណៈសកម្ម និងតម្លាភាព។ របាយការណ៍ និងឯកសារសារទុក្ខទាំងនេះនឹងត្រូវបានធ្វើឡើងជាសាធារណៈ។

៤៤. រាល់តម្លៃដែលទាក់ទងនឹងដំណើការសារទុក្ខនឹងត្រូវបានចងក្រងជាឯកសារ និងបំពេញដោយគណៈកម្មការភូមិ និងស្រុក ក៏ដូចជាផ្នែកអនុវត្តគម្រោងដែលបានបង្ហាញតាមរយៈការពិគ្រោះយោបល់ដែលមានតម្លាភាព។ ឯកសារ និងរបាយការណ៍សារទុក្ខទាំងនេះនឹងត្រូវបានធ្វើឡើងដោយសាធារណៈ។ រាល់ការចំណាយទាក់ទងទៅនឹងដំណើការសារទុក្ខត្រូវបានរ៉ាប់រងដោយអ្នកតវ៉ា និងតំណាងរបស់ពួកគេដែលត្រូវបានធានារ៉ាប់រងដោយអ្នកអភិវឌ្ឍន៍។ ដំណើការសារទុក្ខត្រូវបានរៀបរាប់ដូចខាងក្រោមៈ

| នីតិវិធី | យុត្តាធិការ | ពេលវេលានៃការឆ្លើយតប | ផ្នែកទទួលខុសត្រូវ/ស្ថាប័ន | ការវាស់វែង/ឯកសារ |
|---|---|---|---|---|
| ជំហានទី ១ ថ្នាក់ភូមិ | កន្លែងសាធារណៈដើម្បីធ្វើការតវ៉ា/អ្នកទទួលផល រឺ ប្រជាជនដែលទទួលរងនូវផលប៉ះពាល់។ | រយៈពេល ៥ ថ្ងៃ | អ្នកដឹកនាំភូមិ និងគណៈកម្មការភូមិ | ការសរសេររបាយការណ៍នៃសារទុក្ខ តាមរយៈជំនួយពីផ្នែកអនុវត្តគម្រោង។<br><br>ដាក់ជូនប្រចាំត្រីមាសនៃបញ្ជីឈ្មោះ និងព័តិមានហេតុផលអំពីការតវ៉ានានា មូលហេតុនៃការតវ៉ា ថ្ងៃ ខែ ឆ្នាំនៃការតវ៉ាដែលបានដាក់ និងដំណោះស្រាយទៅកាន់ផ្នែកអនុវត្តគម្រោង។ |
| ជំហានទី ២ ថ្នាក់ស្រុក | ការិយាល័យរបស់អាជ្ញាធរស្រុក | រយៈពេល ១៥ ថ្ងៃ | អាជ្ញាធរស្រុក/ផ្នែកគ្រប់គ្រងគម្រោង | ការសរសេររបាយការណ៍នៃសារទុក្ខពីគណៈ-កម្មការភូមិ តាមរយៈជំនួយពីផ្នែកអនុវត្តគម្រោង<br><br>ដាក់ជូនប្រចាំត្រីមាស នៃបញ្ជីឈ្មោះ និងព័តិមានហេតុផលអំពីការតវ៉ានានា មូលហេតុនៃការតវ៉ា |

| | | | | |
|---|---|---|---|---|
| | | | | ថ្ងៃ ខែ ឆ្នាំនៃការតវ៉ាដែលបានដាក់ និងដំណោះស្រាយទៅកាន់ផ្នែកអនុវត្តគម្រោង។ |
| ជំហានទី ៣ ថ្នាក់ខេត្ត | ការិយាល័យរបស់អាជ្ញាធរខេត្ត | រយៈពេល ១០ ថៃ | អាជ្ញាធរខេត្ត/ ផ្នែកគ្រប់គ្រងគម្រោង | ការសរសេររបាយការណ៍នៃសារទុក្ខពីគណៈ-កម្មការភូមិ និងអាជ្ញាធរស្រុកតាមរយៈជំនួយពីផ្នែកអនុវត្តគម្រោង<br>ដាក់ជូនប្រចាំត្រីមាស នៃបញ្ជីឈ្មោះ និងព័ត៌មានហេតុផលអំពីការតវ៉ានានា មូលហេតុនៃការតវ៉ា ថ្ងៃ ខែ ឆ្នាំនៃការតវ៉ាដែលបានដាក់ និងដំណោះស្រាយទៅកាន់ផ្នែកអនុវត្តគម្រោង។ |

## ឧបសម្ព័ន្ធទី ១. សេចក្ដីសង្ខេបគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

១. គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គមានគោលបំណងដើម្បីបង្កើតឧទាហរណ៍សំខាន់ៗ នៃការអនុវត្ត គ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនៅតាមអាងទន្លេមេគង្គផ្នែកខាងក្រោម ថ្នាក់តំបន់ ជាតិ និងថ្នាក់ខេត្ត។ សកម្មភាពនានានឹងត្រូវបានអនុវត្តតាមរយៈសមាសភាព ៣ ដូចខាងក្រោមៈ

- សមាសភាពទី ១. ការគ្រប់គ្រងធនធានទឹកថ្នាក់តំបន់- សមាសភាពនេះមានគោលបំណងដើម្បីបង្កើនការយល់ដឹង និងសហប្រតិបត្តិការស្ដីពីគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនៅក្នុងចំណោមបណ្ដាប្រទេសផ្នែកខាងក្រោមនៃទន្លេមេគង្គ។ សកម្មភាពសំខាន់ៗគួរត្រូវរួមបញ្ចូលទាំងជំនួយបច្ចេកទេស ការកសាងសមត្ថភាព សិក្ខាសាលា/ការប្រជុំ ទស្សនៈកិច្ចសិក្សា និងមិនទំនងជាមានផលប៉ះពាល់ទៅលើគោលនយោបាយនានារបស់សុវត្ថិភាពធនាគារ។
- សមាសភាពទី ២. ការគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ- គោលបំណងសំខាន់គឺដើម្បីគាំទ្រគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនៅក្នុប្រទេសឡាវ ដែលមានបរិមាណជាង ៣០ ភាគរយនៃលំហូររបស់អាងទន្លេមេគង្គ។ សកម្មភាពសំខាន់ៗនឹងរួមមានទាំងជំនួយបច្ចេកទេស សិក្ខាសាលា/ការប្រជុំ ទស្សនៈកិច្ចសិក្សា និងសកម្មភាពនៃការកសាងសមត្ថភាពនានា ដូចជាសម្ភារៈ និងយានយន្ត និងការស្ដាបនាឡើងវិញនូវការិយាល័យ/វិសំណង់តូចៗ និងនិងមិនទំនងជាមានផលប៉ះពាល់ទៅលើគោលនយោបាយនានារបស់សុវត្ថិភាពធនាគារ។
- ***សមាសភាពទី ៣. ការគ្រប់គ្រងធនធានទឹក និងព្រៃលិចទឹកត្រូវបានលើកកំពស់នៅតាមតំបន់សំខាន់ៗ ថ្នាក់តំបន់:*** សមាសភាពមានគោលបំណងដើម្បីបង្ហាញនូវការអនុវត្តដែលជោគជ័យនៃការអនុវត្តគម្រោងគ្រប់គ្រង ធនធានទឹកចម្រុះទន្លេមេគង្គៈ (ក). ការគ្រប់គ្រងព្រៃលិចទឹកនៅតាមទន្លេមេគង្គដែលបានជ្រើសរើសនៅក្នុងប្រទេសឡាវ និង (ខ). ការអភិវឌ្ឍន៍នៃការគ្រប់គ្រងដែនជលផលរួមត្រួតស៊ីគ្នានៅក្នុងតំបន់អាទិភាពនានានៃប្រទេសកម្ពុជា និងឡាវ។ សកម្មនានានឹងត្រូវបានអនុវត្តតាមរយៈអនុសមាសភាព ៣ ដូចខាងក្រោម៖

*(៣.១). ការគ្រប់គ្រងព្រៃលិចទឹក និងអាងទន្លេនៅក្នុងផ្នែកខាងក្រោមនៃ Xe Bang Fai (XBF) និង Xe Bang Hian (XBH) នៅក្នុងប្រទេសឡាវ សកម្មភាពសំខាន់ៗគួរបញ្ចូលៈ*

(៣.១.១). គាំទ្រការអភិវឌ្ឍន៍នៃស្ថាប័នអាងទន្លេ និងគម្រោងរៀបចំផែនការដោយផ្ដោតទៅលើ " ទីតាំងក្ដៅ "។ ការអភិវឌ្ឍន៍នៃផែនការគ្រប់គ្រងសំរាប់ផ្នែកខាងក្រោមនៃ XBF និង XBH ដោយផ្ដោត

ទៅលើចំណុចភ្ជាប់ភ្ជារវាងដែនានា និងទន្លេមេគង្គ។ គម្រោងគួរគាំទ្រជំនួយបច្ចេកទេស បណ្តុះបណ្តាល និងសម្ភារៈ និងការជួសជុលការិយាល័យ។

(៣.១.២). ការធ្វើអោយប្រសើរឡើងវិញនូវច្រកទ្វារដែលមានស្រាប់ដើម្បីជួសជុលការគ្រប់គ្រងព្រៃលិចទឹក និងការបំលាស់ទីរបស់ត្រីទៅលើដី ១៤ ០០០ ហិចតា និងការស្តាបនាឡើងវិញនៃរចនាប្រព័ន្ធធារាសាស្ត្រដើម្បី គាំទ្រការស្តារឡើងវិញនៃការដាំដុះស្រូវតាមតំបន់ព្រៃលិចទឹក និងការពងកូនរបស់ត្រីនៅលើដី ៨៥០០ ហិចតា ជាមួយនឹងការផ្តល់ការគាំទ្រដើម្បីលើកកំពស់ មានទឹកគ្រប់គ្រាន់ដើម្បីបង្កបង្កើនផលស្រូវ តាមរយៈការងារស៊ីវិល បំពាក់ឧបករណ៍ និងគាំទ្រការផ្សព្វផ្សាយ និង

(៣.១.៣). ការផ្តល់នូវការគាំទ្រភស្តុភារទៅដល់រដ្ឋបាលខេត្តនៃរដ្ឋបាលបរិស្ថាន និងធនធានទឹក និងក្រសួងកសិកម្ម (នាយកដ្ឋានធារាសាស្ត្រ និងជលផល) សំរាប់ការអនុវត្តអនុសមាសភាព។

(៣.២). ការគាំទ្រដើម្បីការគ្រប់គ្រងដែលបានលើកកំពស់នៃធនធានទឹកនៅក្នុងប្រទេសឡាវ និងកម្ពុជាបង្ហាញីភាពសំបូរនៃកន្លែងពងកូនសំរាប់ទន្លេមេគង្គ និងសកម្មភាពសំខាន់ៗគួររួមបញ្ចូលៈ

៣.២.១. គាំទ្រការគ្រប់គ្រងវិស័យជលផលតាមបែបសហគមន៍នៅខេត្តចំប៉ាសាក់ អាតាប៉ឺ និងសេកុង (ប្រទេសឡាវ) រួមទាំងការអភិវឌ្ឍន៏នៃផែនការគ្រប់គ្រងដោយមានការចូលរួម ការបណ្តុះបណ្តាលលើការអភិរក្ស និងគ្រប់គ្រងវិស័យជលផល ការអនុវត្ត និងអភិវឌ្ឍន៏ជំរើសមុខរបរ និងផែនការអភិវឌ្ឍន៏ឃុំ រួមទាំងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធជនបទ។ គម្រោងគួរផ្តល់នូវការបណ្តុះបណ្តាល បង្កើតនូវយន្តការសារទុក្ខ ការខិតទៅដល់សហគមន៏ តម្លៃនៃការអនុវត្ត ទំនិញ និងការងារសង្គម។

៣.២.២. ការពង្រឹងការគ្រប់គ្រងវិស័យជលផលសារធារណៈនៅតាមស្ថាប័នជលផលថ្នាក់ខេត្ត និងស្រុក (ក). ការប្រមូលទិន្នន័យផលចាប់ តាមដាន និងនីតិវិធី ជាមួយសហគមន៏ (ខ). ពង្រីកសកម្មភាព និង (គ). គាំទ្រវារីវប្បកម្មប្រភេទត្រីក្នុងស្រុក និងការប្រលែងត្រីទ្បោងធម្មជាតិពីស្ថានីយ៏ភ្ញាស់កូនត្រី ជំនួយបច្ចេកទេស និងទស្សនៈកិច្ចសិក្សាដល់កសិករ។ គម្រោងគួរផ្តល់នូវថវិការ ការងារ ការបណ្តុះបណ្តាល និងតម្លៃប្រតិបត្តិ និង

៣.២.៣. ផ្តល់នូវការគាំទ្រដើម្បីការគ្រប់គ្រងសមាសភាពទៅដល់នាយកដ្ឋានជលផលនៅខេត្តចំប៉ាសាក់ ប៉ាក់សេ (ប្រទេសឡាវ) និងនៅភ្នំពេញ (ប្រទេសកម្ពុជា) រួមទាំងតម្លៃប្រតិបត្តិ និងការកែលំអរការិយាល័យ។

២. គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គគឺជាគម្រោងមួយដែលនឹងត្រូវបានអនុវត្តរយៈពេល ៦ ឆ្នាំ (២០១១- ២០១៦)។ គណៈកម្មការទន្លេមេគង្គ តាមរយៈលេខាធិការដ្ឋានរបស់វានឹងជាភ្នាក់ងារអនុវត្តសំរាប់សមាសភាពទី ១ ខណៈដែលភ្នាក់ងារនៅប្រទេសឡាវស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋបាលបរិស្ថាន និងធនធាទឹកនឹងត្រូវអនុវត្តសមាសភាពទី ២ និងអនុសមាសភាពទី ៣-១។ នាយកដ្ឋានបសុព្យាសត្វនៃក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ និងការិយាល័យនៅតាមខេត្តរបស់វាដូចជា ចំប៉ាសាក់ អាតាតប៊ឺ និងសេកុងជាភ្នាក់ងារអនុវត្តសំរាប់អនុសមាសភាពទី ៣-១។ រដ្ឋបាលជលផល នៃ ក្រសួងកសិកម្ម និង រុក្ខាប្រមាញ់ និងនេសាទជាភ្នាក់ងារអនុវត្តសកម្មនៅកម្ពុជា ដែលស្ថិតនៅក្រោមអនុសមាសភាពទី ៣-២។